N.16
30.4.02

# ក

# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០៨-៤-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០៤០២/០៩៤ តែងតាំងឯកឧត្តម **គួច សេងហេង** ជាទីប្រឹក្សាប្រធានរដ្ឋសភា ១០២៧

០៨-៤-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០៤០២/០៩៥ តែងតាំងឯកឧត្តម **គឹម ទិមល** ជាឧបការីប្រធានរដ្ឋសភា ១០២៨

០៨-៤-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០៤០២/០៩៦ តែងតាំងអ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ សុជីវ៉ា** ជាឧបការីប្រធានរដ្ឋសភា ១០២៩

០៨-៤-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០៤០២/០៩៧ តែងតាំងឯកឧត្តម **សាន លុច** ជាឧបការីប្រធានរដ្ឋសភា ១០៣០

១២-៤-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០៤០២/១០១ តែងតាំងឯកឧត្តម **ឡោក ឆាយ** ជាទីប្រឹក្សាផ្ទាល់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ១០៣១

២៥-៤-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០៤០២/១០៧ ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីកម្ម ដល់លោក **លី ប៊ូនីន** (LI BONING) សញ្ជាតិដើមចិន ១០៣២

២៥-៤-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០៤០២/១០៨ តែងតាំងលោកជំទាវ **គឹម សត្ថាវី** ជានាយកសាលាភូមិន្ទចៅក្រម ១០៣៣


## II- រាជរដ្ឋាភិបាល

### អនុក្រឹត្យ


២៥-៤-២០០២ - អនុក្រឹត្យលេខ៣៦ អនក្រ.បក ស្តីពីការកែប្រែរចនាសម្ព័ន្ធនៃមហាវិទ្យាល័យវ៉ាស៊ីនតោនឌីស៊ី ទៅជាវិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង ១០៣៤

២៤-៤-២០០២ - អនុក្រឹត្យលេខ ២០៦ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ១០៣៧

២៥-៤-២០០២ - អនុក្រឹត្យលេខ ២០៧ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិជាកិច្ចបច្ឆាមរណៈ ១០៣៩

16.



២៩-៤-២០០២ - អនុក្រឹត្យលេខ ២០៨ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ១០៤០

២៩-៤-២០០២ - អនុក្រឹត្យលេខ ២០៩ អនក្រ.តត ស្ដីពីការផ្ទេរក្របខ័ណ្ឌតែងតាំងមុខតំណែង និងឋានន្តរសក្តិនាយទាហាន ១០៥០

២៩-៤-២០០២ - អនុក្រឹត្យលេខ ២១០ អនក្រ.តត ស្ដីពីការតែងតាំងសមាសភាព ក្រុមប្រឹក្សា-ភិបាល និងអគ្គនាយកនៃក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា " **កម្ពុជា រ៉េ** " ១០៥១

៣០-៤-២០០២ - អនុក្រឹត្យលេខ ២១១ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ១០៥៣

## III- **ការងារបណ្ដាក្រសួង**

### **ទីស្ដីការរដ្ឋមន្ត្រីក្រសួង ប្រៃសណីយ៍ និងទូរគមនាគមន៍**

២៩-៤-២០០២ - ប្រកាសលេខ ១១១ បទ.ប្រក ស្ដីពីការបង្កើតក្រុមការងាររៀបចំច្បាប់ពង្រាង លើវិស័យទូរគមនាគមន៍ ១០៥៤

២៩-៤-២០០២ - ប្រកាសលេខ ១១៣ បទ.ប្រក ស្ដីពីការតភ្ជាប់រវាងប្រព័ន្ធទូរស័ព្ទ ១០៥៦

# ព្រះរាជក្រឹត្យ

នស/រកត/០៤០២/០៩៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ញាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ១៩៧ រស ចុះថ្ងៃទី ០៩ ខែមករា ឆ្នាំ២០០២

## ត្រាស់បង្គាប់

**មាត្រា១ .-** តែងតាំងឯកឧត្តម គួច សេងហេង ជាទីប្រឹក្សាប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ ។

**មាត្រា២ .-** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

**នរោត្តម សីហនុ**

ពរល.០២.០៨.០០១០៨

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០២

លេខៈ ៩៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៤០២/០៩៥

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ២០៥ រស ចុះថ្ងៃទី ១៨ ខែមិនា ឆ្នាំ២០០២

**ត្រាស់បង្គាប់**

**មាត្រា១** .- តែងតាំងឯកឧត្តម គឹម ទិមល ជាឧបការីប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា២** .- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខ: ៩៤ ច.ល

៣ល. ០២.០៤.០០១០៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០២ ដើម្បីចម្លងចែក

រាជធានីភ្នំពេញ.ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាវី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៤០២/០៩៦

យើង

**ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្ដម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ញាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសេចក្ដីក្រាបបង្គំទូលស្នើសុំរបស់សម្ដេចក្រុមព្រះ **នរោត្ដម រណឫទ្ធិ** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ២២២ រស ចុះថ្ងៃទី ២៣ ខែមិនា ឆ្នាំ២០០២

## ត្រាស់បង្គាប់

**មាត្រា១** .- តែងតាំងអ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ សុជីវ៉ា** ជាឧបការីប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា២** .- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ដលេខានេះតទៅ ។

**ព្រះហស្ដលេខា និង ព្រះរាជលញ្ឆករ**

**នរោត្ដម សីហនុ**

៣៤០.០២.០៤.០០១០៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០២

លេខៈ ៩៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ១មសា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សោ ខី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៤០២/០៩៧

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ២២៣ រស ចុះថ្ងៃទី ២៣ ខែមិនា ឆ្នាំ២០០២

## ត្រាស់បង្គាប់

**មាត្រា១ .-** តែងតាំងឯកឧត្តម សាន លុច ជាឧបការីប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា២ .-** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

៣រក.០២.០៤.០០១០៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០២

លេខៈ ៩៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ.ថ្ងៃទី ០៤ ខែ [illegible] ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ធារាជី តាន់

នស/រកត/០៤០២/១០១

# ព្រះរាជក្រឹត្យ

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបាន អនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់ តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រធានព្រឹទ្ធសភា

-យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ២០០២

## ត្រាស់បង្គាប់

មាត្រា១ : តែងតាំងឯកឧត្តម ឡោក ឆាយ ជាទីប្រឹក្សាផ្ទាល់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈស្មើរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា២ : ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខៈ ៩៦ ច.ល

៣រល.០២.០៤.០០១១៦

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០២

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ.ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សាន់ តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៤០២/១០៧

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **លី ប៊ូនីន** ( LI BONING ) សញ្ជាតិដើមចិន កើតថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៥៨ នៅខេត្តហ៊ូណាំ ប្រទេសចិន ដោយប្តូរយកឈ្មោះថ្មីជា **ឈុន សុធី** ( CHHUN SOTHY ) ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ៕

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ: ៩៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សរ៉ាន់ តាន់

៣រល.០២០៤.០០១១៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០២

# ព្រះរាជក្រឹត្យ

នស/រកត/០៤០២/១០៨

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងលោកជំទាវ **គិម សន្ធាវី** ជានាយកសាលាភូមិន្ទចៅក្រម មានឋានៈស្មើ អគ្គនាយក ។

**មាត្រា ២:** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣:** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ៕

ព្រះហស្ថលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខៈ ៩៨ ច.ល

ដើម្បីចម្លងចែក

៣រក-០៤០៤-០០១១៨

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០២

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] តាន់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៣៦...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែប្រែរចនាសម្ព័ន្ធនៃមហាវិទ្យាល័យវ៉ាស៊ីនតោនឌីស៊ី ទៅជាវិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦.០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អន.ក្រ ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតមហាវិទ្យាល័យវ៉ាស៊ីនតោនឌីស៊ី
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និង កីឡា

# សំ រេ ច

**មាត្រា ១ :** អនុញ្ញាតអោយ មហាវិទ្យាល័យវ៉ាស៊ីនតោនឌីស៊ី កែប្រែរចនាសម្ព័ន្ធ ទៅជា វិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង (Institute of Management Sciences) ហៅកាត់ជាភាសាខ្មែរ វ.វ.គ. និង ជាភាសាអង់គ្លេស I.M.S. ។ វិទ្យាស្ថាននេះ មានទីតាំងមូលដ្ឋាន នៅអាគារជាប់ធនាគារកាណាឌីយ៉ា នៅផ្លូវព្រះកុសុមៈនារីរ័ត្ន ឃុំកំពង់ចាម ស្រុកកំពង់ចាម ក្នុងទីរួមខេត្ត កំពង់ចាម ។ រីឯ មហាវិទ្យាល័យវ៉ាស៊ីនតោនឌីស៊ីខេត្តបាត់ដំបង ត្រូវបានចាត់ទុកជា សាខានៃវិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង វិញ ។

**មាត្រា ២ :** វិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង ធ្វើការបណ្តុះបណ្តាល ថ្នាក់បរិញ្ញាប័ត្រ ដែលមានរយៈពេលសិក្សា ៤ ឆ្នាំ ត្រូវនឹង ១៥០ ក្រេឌីត ជាមធ្យម ។

**មាត្រា ៣ :** វិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង មាន ៣ មហាវិទ្យាល័យ :

១. មហាវិទ្យាល័យគ្រប់គ្រង និង ទេសចរណ៍

២. មហាវិទ្យាល័យពត៌មានវិទ្យា

៣. មហាវិទ្យាល័យ នីតិសាស្ត្រ និង សេដ្ឋកិច្ច

ទៅពេលអនាគត វិទ្យាស្ថាននេះអាចបើក មហាវិទ្យាល័យ ឬសាខា ឬឯកទេសជំនាញ ដ៏ទៃទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាត ពីក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៤ :** លក្ខខណ្ឌទទួលសិស្សអោយចូលរៀន :

វិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង ត្រូវគោរព តាមបទដ្ឋាន របស់ក្រសួង អប់រំ យុវជន និង កីឡា ដែលកំណត់ អំពីការជ្រើសរើសអោយចូលរៀន នៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

**មាត្រា ៥ :** នាយក នៃ វិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង មានភារកិច្ច :

- ជ្រើសរើស សិស្ស និស្សិតអោយចូលរៀន និង ជ្រើសរើស សាស្ត្រាចារ្យ មកបង្រៀន និង បុគ្គលិកបំរើការងារ ។
- គ្រប់គ្រងអោយបានល្អ នូវការបង្រៀន ការងារស្រាវជ្រាវ ឯកសារសិក្សា ការប្រលង និង ការ-ប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្ត តាមសារាចរ និង សេចក្តីណែនាំ របស់រាជរដ្ឋាភិបាល ។
- ធានាអោយបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សា ជូនក្រសួងអប់រំ យុវជន និង កីឡា រៀងរាល់ឆមាស ។

**មាត្រា ៦ :** ក្នុងរចនាសម្ព័ន្ធ នៃវិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង មានក្រុមប្រឹក្សាភិបាលមួយ ទទួលបន្ទុកការងារពិនិត្យនិងសំរេច លើគោលនយោបាយនិងផែនការអភិវឌ្ឍវិទ្យាស្ថាន និងមានក្រុមប្រឹក្សាវិទ្យាសាស្ត្រ

មួយ សំរាប់ពិនិត្យ និង ផ្តល់ការយល់ព្រម លើកម្មវិធីសិក្សា និង ការងារបច្ចេកទេសពាក់ព័ន្ធ ។

**មាត្រា ៧ :** វិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង ត្រូវស្ថិតនៅក្រោម ឱវាទក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៨ :** និស្សិត ដែលរៀនចប់កម្មវិធីសិក្សា របស់វិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង និងទទួលជោគជ័យ ក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្រថ្នាក់បរិញ្ញាប័ត្រ ដែលផ្តល់អោយ ដោយវិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង ហើយត្រូវបានទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីវិទ្យាស្ថាននេះបំពេញ និងអនុវត្ត តាមគោលការណ៍របស់ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៩ :** រដ្ឋមន្ត្រីទទួលបន្ទុកទិស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា អគ្គនាយកដ្ឋានអង្គភាពពាក់ព័ន្ធ និង វិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង មានភារកិច្ចរៀង ៗ ខ្លួន ដើម្បីអនុវត្ត និងប្រតិបត្តិ តាមអនុក្រឹត្យនេះ ។

**មាត្រា ១០ :** អនុក្រឹត្យនេះ មានប្រសិទ្ធិភាព និង គតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

ភ្នំពេញ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាខេត្តកំពង់ចាម
- សាលាខេត្តបាត់ដំបង

" ដើម្បីមុខការ "

- ដូចមាត្រា ៩ " ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧០៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងសុខាភិបាល

## ស ំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ជូនអ្នកឯកទេសវេជ្ជសាស្ត្របារាំង ខ្មែរ និងវិស្វករឯកទេសចិន ចំនួន ០៧ រូប ដែលមានស្នាដៃល្អ និងគុណបំណាច់ខ្ពស់ ក្នុងការអភិវឌ្ឍន៍មន្ទីរពេទ្យកាល់ម៉ែត ជួយបណ្តុះបណ្តាល និង ឧបត្ថម្ភសំភារៈបរិក្ខារតាមស្តង់ដារអន្តរជាតិជាច្រើនទៀត ដល់មន្ទីរពេទ្យដូចមានរាយនាមខាងក្រោមនេះ ÷

**ក_មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ :**

១-លោក **អ៊ែរវេ ដូរីយ៉ាណូ** ( Hervé d 'ORIAN0 ) អគ្គប្រតិភូនាយកគំរោងកម្មវិធី អភិវឌ្ឍន៍មន្ទីរពេទ្យ

២-លោកសាស្ត្រាចារ្យ **យូ គឹមយាន** សាស្ត្រាចារ្យពិគ្រោះយោបល់នៅអាគារជម្ងឺទូទៅ"ក"

**ខ_មេដាយសហមេត្រី** ថ្នាក់ **សេនា :**

១-លោកសាស្ត្រាចារ្យ **ក្លូត ឌុយមួរហ្ស៊ីយេ** ( Claude DUMURGIER ) គ្រូពេទ្យវះកាត់ជំនាញការ ផ្នែកជម្ងឺវះកាត់ "ក" និង "ខ"

២-លោកសាស្ត្រាចារ្យ **គ្រីស្សង់ រ៉ាដ្ឋាត** ( Christian RATHAT ) គ្រូពេទ្យឯកទេសសណ្តំប្រពោធនកម្ម និង សង្គ្រោះជម្ងឺបន្ទាន់

៣-លោកវេជ្ជបណ្ឌិត **ប៉ាស្កាល់ គ្រេប៉ាំង** ( Pascal CREPIN ) នាយកកម្មវិធីជំនួយអង្គការគ្រូពេទ្យពិភពលោកប្រចាំនៅកម្ពុជា

៤-លោកវេជ្ជបណ្ឌិត **ព្យែរ រេហ្សីសម៉ារតាំង** ( Pierre - Régis Martin ) គ្រូពេទ្យអង្គការគ្រូពេទ្យពិភពលោក

**គ-មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ :**

១-លោក **តុង គាំង** ( TONG GANG ) វិស្វករ ឯកទេសជួសជុលគ្រឿងបរិក្ខារ និង ម៉ាស៊ីនលាងឈាម

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួង សុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/ ៖

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតម្លើងឋានន្តរសក្តិជាកិច្ចបច្ឆាមរណៈ

~~~~~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

## សំរេច

**មាត្រា១ :** ត្រូវបានតម្លើងឋានន្តរសក្តិ ថ្នាក់វរសេនីយ៍ឯក ជាកិច្ចបច្ឆាមរណៈជូនសព

-វរសេនីយ៍ទោ ប្រាក់ ធូនទុឡន៍ អត្តលេខ ០០២៤៨១ មេបញ្ជាការរង កងហោះឧទ្ធម្ភាគចក្រ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែមេសា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>**ចម្លងជូន**</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ
~~~~~~~

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២០៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

~~~~~~~~~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងពតិមាន

## សំ រេ ច

**មាត្រា ១** : ត្រូវបានបំពាក់មេដាយការងារតាមលំដាប់ថ្នាក់ជូនមន្ត្រីរាជការចំនួន ២៤៥រូប នៃក្រសួងពតិមាន ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចឆ្នាំ ២០០១ ដូចមានរាយនាមខាងក្រោមនេះ ÷

ក -មេដាយប្រាក់ការងារ :

| | | | | |
|---|---|---|---|---|
| ១ - | លោក | អន | ប៊ុណ្ណារឿន | ប្រធាននាយកដ្ឋាន |
| ២ - | លោក | សោម | ប៊ូរ៉ា | អនុប្រធាននាយកដ្ឋាន |
| ៣ - | លោក | ធន់ | សារឹម | អនុប្រធាននាយកដ្ឋាន |
| ៤ - | លោក | ហ៊ីន | ទីរៈ | អនុប្រធាននាយកដ្ឋាន |
| ៥ - | លោក | សាន | ហួត | អនុប្រធាននាយកដ្ឋាន |
| ៦ - | លោក | រ៉ាំង | សុខ | អនុប្រធាននាយកដ្ឋាន |
| ៧ - | លោក | ផាន់ | សារិន | អនុប្រធាននាយកដ្ឋាន |
| ៨ - | លោក | ម៉ាល់ | អាន | អនុប្រធាននាយកដ្ឋាន |
| ៩ - | លោក | ឡិក | សមប្រាថ្នា | អធិការរង |
~~~~~~~~~~~

| | | | | |
|---|---|---|---|---|
| ១០ - | លោក | ជា | ផារិទ្ធ | អនុប្រធាននាយកដ្ឋាន |
| ១១ - | លោក | តូច | ចិត្រា | អនុប្រធាននាយកដ្ឋាន |
| ១២ - | លោក | សារឹម | ប៊ុណ្ណាមី | អនុប្រធាននាយកដ្ឋាន |
| ១៣ - | លោក | សុខ | សារឿន | អនុប្រធាននាយកដ្ឋាន |
| ១៤ - | លោក | ហ៊ីម | វិបុលផល | អនុប្រធាននាយកដ្ឋាន |
| ១៥ - | លោក | គីម | យ៉ាន | អនុប្រធាននាយកដ្ឋាន |
| ១៦ - | លោក | ឌុង | ផន | អនុប្រធាននាយកដ្ឋាន |
| ១៧ - | លោកស្រី | នឹង | គីមស្រេង | អនុប្រធាននាយកដ្ឋាន |
| ១៨ - | លោក | ប៊ុន | ហឿម | អនុប្រធាននាយកដ្ឋាន |
| ១៩ - | លោក | ម៉ាន់ | សារ៉ាន់ | ប្រធានមន្ទីរពតិមាន ខេត្តកំពង់ធំ |
| ២០ - | លោក | ម៉ម | ឈឿម | ប្រធានមន្ទីរពតិមាន ខេត្តតាកែវ |

## ខ ~ មេដាយសេរីវឌ្ឍនភាពរូបនរ :

| | | | | |
|---|---|---|---|---|
| ១ - | លោក | មាស | គឹមសួន | ប្រធានការិយាល័យ |
| ២ - | លោក | ឈឹម | សារ៉េត | ប្រធានការិយាល័យ |
| ៣ - | លោក | ខាត់ | រិទ្ធី | ប្រធានការិយាល័យ |
| ៤ - | លោក | អ៊ូច | សុខបាន | ប្រធានការិយាល័យ |
| ៥ - | លោក | សុខ | សារឿន | ប្រធានការិយាល័យ |
| ៦ - | លោក | មាស | ចាន់រក្សា | ប្រធានការិយាល័យ |
| ៧ - | លោក | ស៊ី | បរិញ្ញា | ប្រធានការិយាល័យ |
| ៨ - | លោក | អ៊ួន | សុខុម | ប្រធានការិយាល័យ |
| ៩ - | លោក | ប៉ាក់ | គួយ | ប្រធានការិយាល័យ |
| ១០ - | កញ្ញា | ពេជ្រ | ស្ថាណនារីណា | ប្រធានការិយាល័យ |
| ១១ - | លោក | អ៊ុក | ច្រឹង | អនុប្រធានមន្ទីរពតិមាន ខេត្តក្រចេះ |
| ១២ - | លោកស្រី | យក់ | សាម៉េន | អនុប្រធានមន្ទីរពតិមាន ខេត្តកំពង់ចាម |
| ១៣ - | លោក | ទ័ន | ស្រៀន | អនុប្រធានមន្ទីរពតិមាន ខេត្តកំពង់ចាម |
| ១៤ - | លោក | ឌួច | ស្រ៊ុន | អនុប្រធានមន្ទីរពតិមាន ខេត្តរតនៈគីរី |
| ១៥ - | លោក | សំ | ផុន | អនុប្រធានមន្ទីរពតិមាន ខេត្តកំពត |

| | | | | |
|---|---|---|---|---|
| ១៦ - | លោក | ញ៉ូវ | សារឯម | អនុប្រធានមន្ទីរពត៌មាន ខេត្តកំពត |
| ១៧ - | លោក | សេង | សុធារ | អនុប្រធានមន្ទីរពត៌មានរាជធានីភ្នំពេញ |
| ១៨ - | លោក | នុំ | សុខ | អនុប្រធានមន្ទីរពត៌មានក្រុងប៉ៃលិន |
| ១៩ - | លោក | យូ | យិន | អនុប្រធាន មន្ទីរពត៌មាន ខេត្តព្រះវិហារ |
| ២០ - | លោក | អៀង | ជេដ្ឋ | អនុប្រធានមន្ទីរ ពត៌មាន ខេត្តព្រៃវែង |
| ២១ - | លោក | ខួន | សុមេត | អនុប្រធានមន្ទីរពត៌មាន ខេត្តសៀមរាប |
| ២២ - | លោកស្រី | សុខ | សួន | អនុប្រធានមន្ទីរពត៌មាន ខេត្តសៀមរាប |
| ២៣ - | លោកស្រី | គង់ | សារិយា | អនុប្រធានមន្ទីរ ពត៌មាន ខេត្តកណ្តាល |
| ២៤ - | លោក | ស៊ាន | សារ៉ាន់ | អនុប្រធានមន្ទីរពត៌មាន ខេត្តពោធិសាត់ |
| ២៥ - | លោក | ខឹ | សាលី | អនុប្រធានមន្ទីរពត៌មាន ខេត្តមណ្ឌលគីរី |
| ២៦ - | លោក | ប៊ុនឡឹង | ចុយ | អនុប្រធានមន្ទីរពត៌មាន ខេត្តមណ្ឌលគីរី |
| ២៧ - | លោក | ប្រាក់ | គង់ | អនុប្រធានមន្ទីរពត៌មានខេត្តស្វាយរៀង |
| ២៨ - | លោក | ម៉ៅ | ប៊ុណ្ណា | អនុប្រធានមន្ទីរពត៌មានខេត្តស្វាយរៀង |
| ២៩ - | លោក | សៃ | សារី | អនុប្រធានមន្ទីរពត៌មានខេត្ត ស្ទឹងត្រែង |
| ៣០ - | លោក | អ៊ុក | ធារី | អនុប្រធានមន្ទីរពត៌មានខេត្ត ស្ទឹងត្រែង |
| ៣១ - | លោក | កែវ | ពេជ្រនិមល | អនុប្រធានមន្ទីរពត៌មានខេត្ត កំពង់ឆ្នាំង |
| ៣២ - | លោក | ចាន់ | ហាន | អនុប្រធានមន្ទីរពត៌មានខេត្ត បន្ទាយមានជ័យ |
| ៣៣ - | លោក | អ៊ុក | សឿន | អនុប្រធានមន្ទីរពត៌មានខេត្ត បន្ទាយមានជ័យ |
| ៣៤ - | លោក | ញ៉ៀម | នុំ | អនុប្រធានមន្ទីរពត៌មាន ខេត្តកំពង់ស្ពឺ |
| ៣៥ - | លោក | នី | ទុឡា | អនុប្រធានមន្ទីរពត៌មាន ខេត្តកំពង់ស្ពឺ |
| ៣៦ - | លោក | សែម | សុខា | អនុ.ប្រធានមន្ទីរពត៌មាន ខេត្តបាត់ដំបង |
| ៣៧ - | លោក | សៅ | រិន | អនុ.ប្រធានមន្ទីរពត៌មាន ខេត្តបាត់ដំបង |
| ៣៨ - | លោក | សុខ | នី | អនុប្រធានមន្ទីរពត៌មាន ក្រុងព្រះសីហនុ |
| ៣៩ - | លោក | តាប់ | តាំងអ៊ាង | អនុប្រធានមន្ទីរពត៌មាន ខេត្តកំពង់ធំ |
| ៤០ - | លោកស្រី | យស់ | ថានរី | អនុប្រធានមន្ទីរពត៌មាន ខេត្តកំពង់ធំ |
| ៤១ - | លោក | អ៊ឹម | សំភ្លី | អនុប្រធានមន្ទីរពត៌មាន ខេត្តកោះកុង |
| ៤២ - | លោក | សៅ | សារិទ្ធ | អនុប្រធានមន្ទីរពត៌មាន ខេត្តតាកែវ |

| | | | | |
|---|---|---|---|---|
| ៤៣ - | លោក | គង់ | ម៉ូនីរ័ត្ន | អនុប្រធានមន្ទីរពត៌មាន ខេត្តតាកែវ |
| ៤៤ - | លោក | អ៊ិច | ស៊ីថា | អនុប្រធានការិយាល័យ |
| ៤៥ - | លោក | ហឿន | សេងហាក់ | អនុប្រធានការិយាល័យ |
| ៤៦ - | លោក | ឌុយ | សុខចេង | អនុប្រធានការិយាល័យ |
| ៤៧ - | លោក | គល់ | សេងអ៊ីម | អនុប្រធានការិយាល័យ |
| ៤៨ - | លោកស្រី | ទង់ | យ៉ាវី | អនុប្រធានការិយាល័យ |
| ៤៩ - | លោក | ឈឹម | រិទ្ធី | អនុប្រធានការិយាល័យ |
| ៥០ - | លោក | តាំង | សារះ | អនុប្រធានការិយាល័យ |
| ៥១ - | លោកស្រី | ជា | សុខហួយ | អនុប្រធានការិយាល័យ |
| ៥២ - | លោក | ជា | សារី | អនុប្រធានការិយាល័យ |
| ៥៣ - | លោកស្រី | គីម | សេងអាត | អនុប្រធានការិយាល័យ |
| ៥៤ - | លោក | យាន | ស៊ុន្នី | អនុប្រធានការិយាល័យ |
| ៥៥ | លោក | ខៀវ | នី | អនុប្រធានការិយាល័យ |
| ៥៦ - | លោក | គ្រឿង | ប៊ុនរ៉េន | អនុប្រធានការិយាល័យ |
| ៥៧ - | លោក | ម៉ក់ | ទិដ្ឋះ | អនុប្រធានការិយាល័យ |
| ៥៨ - | លោក | សៅ | សុវណ្ណ | អនុប្រធានការិយាល័យ |
| ៥៩ - | លោក | សាន | សុលី | អនុប្រធានការិយាល័យ |
| ៦០ - | លោក | អឿង | សុខ | អនុប្រធានការិយាល័យ |
| ៦១ - | លោក | សារឹម | គក់ | អនុប្រធានការិយាល័យ |
| ៦២ - | លោក | មាស | សាមឿន | អនុប្រធានការិយាល័យ |
| ៦៣ - | លោកស្រី | ឈុន | សុខានី | អនុប្រធានការិយាល័យ |
| ៦៤ - | លោកស្រី | រស់ | សូផាត | អនុប្រធានការិយាល័យ |
| ៦៥ - | លោក | ឥន្ទ | តារ៉ានី | អនុប្រធានការិយាល័យ |
| ៦៦ - | លោក | ម៉ី | ចំរើន | អនុប្រធានការិយាល័យ |
| ៦៧ - | លោកស្រី | ក្អុច | មារតី | អនុប្រធានការិយាល័យ |
| ៦៨ - | កញ្ញា | កែវ | សុណា | អនុប្រធានការិយាល័យ |
| ៦៩ - | លោកស្រី | ឃុន | ស៊ីផុន | អនុប្រធានការិយាល័យ |

| | | | | |
|---|---|---|---|---|
| ៧០ - | លោក | អន | ឌូក | អនុប្រធានការិយាល័យ |
| ៧១ - | លោក | គង់ | ហួន | អនុប្រធានការិយាល័យ |
| ៧២ - | លោក | ប៉ែន | សាម៉េត | អនុប្រធានការិយាល័យ |
| ៧៣ - | លោក | គង់ | សាម៉េង | ប្រធានស្នាក់ការខេត្តពោធិសាត់ |
| ៧៤ - | លោក | ហាស់ | សុភិន | ប្រធានស្នាក់ការខេត្តបន្ទាយមានជ័យ |
| ៧៥ - | លោក | ឡេង | ហុក | ប្រធានស្នាក់ការខេត្តបាត់ដំបង |
| ៧៦ - | លោក | ម៉ាន | ឆប | ប្រធានការិយល័យពតិមាន ខេត្ត |
| ៧៧ - | លោក | ឡាយ | ចេងលៀង | ប្រធានការិយាល័យពតិមាន ខេត្ត |
| ៧៨ - | លោក | ចាវ | គីមនិត | ប្រធានការិយាល័យពតិមាន ខេត្ត |
| ៧៩ - | លោក | សុខ | ហម | ប្រធានការិយាល័យពតិមាន ខេត្ត |
| ៨០ - | លោក | សៅ | ជិន | ប្រធានការិយាល័យពតិមាន ខេត្ត |
| ៨១ - | លោក | ឆាត់ | ខូនឈាង | ប្រធានការិយាល័យពតិមាន ខេត្ត |
| ៨២ - | លោក | ប៉ែន | ជីម | ប្រធានការិយាល័យពតិមាន ខេត្ត |
| ៨៣ - | លោកស្រី | ម៉ម | ណារី | អនុប្រធានការិយាល័យពតិមាន ខេត្ត |
| ៨៤ - | លោក | ស៊ុម | លើម | អនុប្រធានការិយាល័យពតិមាន ខេត្ត |
| ៨៥ - | លោក | ម៉ៅ | សាវ៉ាន | អនុប្រធានការិយាល័យពតិមាន ខេត្ត |
| ៨៦ - | លោក | ឡុង | ឈុនឡៃ | អនុប្រធានការិយាល័យពតិមាន ខេត្ត |
| ៨៧ - | លោកស្រី | អ៊ុក | ប៊ុណ្ណា | អនុប្រធានការិយាល័យពតិមាន ខេត្ត |
| ៨៨ - | លោកស្រី | យូ | ស៊ីថា | អនុប្រធានការិយាល័យពតិមាន ខេត្ត |
| ៨៩ - | លោក | សុខ | ខេង | អនុប្រធានការិយាល័យពតិមាន ខេត្ត |
| ៩០ - | លោក | ស្រី | វង្ស | អនុប្រធានការិយាល័យពតិមាន ខេត្ត |
| ៩១ - | លោក | អោក | សំណាង | អនុប្រធានការិយាល័យពតិមានខេត្ត |
| ៩២ - | លោក | យី | សារ៉ាយ | អនុប្រធានការិយាល័យ |
| ៩៣ - | លោក | ឡុង | ហាន | ប្រធានការិយាល័យស្រុក |
| ៩៤ - | លោក | ម៉ៅ | ឃោ | ប្រធានការិយាល័យស្រុក |
| ៩៥ - | លោក | អ៊ុង | យុទ្ធ | ប្រធានការិយាល័យស្រុក |
| ៩៦ - | លោក | សុខ | វង់ | ប្រធាន.ការិ យាល័យស្រុក |

| | | | | |
|---|---|---|---|---|
| ៩៧ - | កញ្ញា | យិន | ស៊ីថា | មន្ត្រី |
| ៩៨ - | លោកស្រី | វណ្ណ | ចាន់ណារី | មន្ត្រី |
| ៩៩ - | កញ្ញា | ផេង | ធីតា | មន្ត្រី |
| ១០០ - | កញ្ញា | តាន់ | ឆៃវណ្ណា | មន្ត្រី |
| ១០១ - | លោក | សោម | ជឿន | មន្ត្រី |
| ១០២ - | លោក | ឡាយ | ម៉ុនលី | មន្ត្រី |
| ១០៣ - | លោកស្រី | ពេជ្រ | សុខា | មន្ត្រី |
| ១០៤ - | លោកស្រី | ជ័យ | សាំងអាង | មន្ត្រី |
| ១០៥ - | លោក | ហ៊ុន | ផល្គុន | មន្ត្រី |
| ១០៦ - | អ្នកស្រី | ឈឹម | វិសុទ្ធដារី | មន្ត្រី |
| ១០៧ - | លោក | អ៊ុច | គឹមយ៉ានី | មន្ត្រី |
| ១០៨ - | លោក | អ៊ុំ | ឆៃរី | មន្ត្រី |
| ១០៩ - | លោក | គឹម | ហួន | មន្ត្រី |
| ១១០ - | កញ្ញា | ភួង | ដាវី | មន្ត្រី |
| ១១១ - | លោកស្រី | ហុង | លក្ស្មី | មន្ត្រី |
| ១១២ - | លោក | ឈុន | សារ៉ាត | មន្ត្រី |
| ១១៣ - | លោក | ម៉ៅ | ថុន | មន្ត្រី |
| ១១៤ - | លោក | សេក | ពុធ | មន្ត្រី |
| ១១៥ - | លោក | ដួង | សាវី | មន្ត្រី |
| ១១៦ - | លោក | យឹង | ឈុន | មន្ត្រី |
| ១១៧ - | លោក | ឡេង | អាន | មន្ត្រី |
| ១១៨ - | កញ្ញា | ស៊ូ | សារ៉េត | មន្ត្រី |
| ១១៩ - | លោក | ជា | ឈាង | មន្ត្រី |
| ១២០ - | លោក | ពេជ្រ | ណារិទ្ធ | មន្ត្រី |
| ១២១ - | លោកស្រី | ប្រាក់ | អេលីរតនា | មន្ត្រី |
| ១២២ - | លោក | ជួន | ណាង | មន្ត្រី |
| ១២៣ - | លោក | អ៊ូ | សំណាង | មន្ត្រី |

| | | | | |
|---|---|---|---|---|
| ១២៤ - | លោក | យស | សុភាព | មន្ត្រី |
| ១២៥ - | លោកស្រី | រស់ | ណ្ហួយ | មន្ត្រី |
| ១២៦ - | លោកស្រី | ស៊ីរិត | សុមនា | មន្ត្រី |
| ១២៧ - | លោកស្រី | ចាប | ផាត | មន្ត្រី |
| ១២៨ - | លោកស្រី | សាន់ | ណារ៉ាឡុង់ឌី | មន្ត្រី |
| ១២៩ - | លោក | ហែម | ប៊ូរិន | មន្ត្រី |
| ១៣០ - | លោក | ប្រាក់ | សំអេង | មន្ត្រី |
| ១៣១ - | លោក | ហ៊ុ | សារ៉ែន | មន្ត្រី |
| ១៣២ - | លោក | ឆិត្យ | ហែម | មន្ត្រី |
| ១៣៣ - | លោក | សន | សមសៀង | មន្ត្រី |
| ១៣៤ - | លោក | សុត | ចាន់ធឿន | មន្ត្រី |
| ១៣៥ - | លោក | អ៊ុក | សុផល | មន្ត្រី |
| ១៣៦ - | លោកស្រី | គង់ | សាវី | មន្ត្រី |
| ១៣៧ - | លោកស្រី | សន | សំអ៊ិន | មន្ត្រី |
| ១៣៨ - | លោកស្រី | ស៊ឹម | ពៅ | មន្ត្រី |
| ១៣៩ - | លោកស្រី | រស់ | គន្ធា | មន្ត្រី |
| ១៤០ - | លោក | ឈន់ | ស៊ុជី | បន្ត្រី |
| ១៤១ - | លោក | ខ្វាន់ | ធេពកោសល្យ | មន្ត្រី |
| ១៤២ - | លោក | លី | ចន្ថា | មន្ត្រី |
| ១៤៣ - | លោក | ម៉ិញ | វិចិត្រ | មន្ត្រី |
| ១៤៤ - | លោក | ឈុន | ស៊ុន | មន្ត្រី |
| ១៤៥ - | លោក | សឿ | សាវុធ | មន្ត្រី |
| ១៤៦ - | លោក | ឆិត | លី | មន្ត្រី |
| ១៤៧ - | លោក | ថុក | អ៊ួង | មន្ត្រី |
| ១៤៨ - | លោក | ប៊ុន | ផេង | មន្ត្រី |
| ១៤៩ - | លោក | នួច | លាង | មន្ត្រី |
| ១៥០ - | លោកស្រី | នេស | សុខចំន្ទ | មន្ត្រី |

| | | | | |
|---|---|---|---|---|
| ១៥១ - | លោកស្រី | មាន | សារ៉ា | មន្ត្រី |
| ១៥២ - | លោក | ព្រុំ | សារ៉ែន | មន្ត្រី |
| ១៥៣ - | លោក | គង | សារួន | មន្ត្រី |
| ១៥៤ - | កញ្ញា | អ៊ុំ | ចាន់ធឿន | មន្ត្រី |
| ១៥៥ - | លោកស្រី | ប៊ិច | ឧត្តរី | មន្ត្រី |
| ១៥៦ - | លោកស្រី | ស៊ិន | ឡី | មន្ត្រី |
| ១៥៧ - | លោកស្រី | អ៊ុង | គីមហ៊ិន | មន្ត្រី |
| ១៥៨ - | កញ្ញា | សេក | សាវឿន | មន្ត្រី |
| ១៥៩ - | លោក | លឹម | សុខុន | មន្ត្រី |
| ១៦០ - | លោកស្រី | ម៉ៅ | ម៉ុលដាវី | មន្ត្រី |
| ១៦១ - | លោក | ប៉ែន | ផលគុណ | មន្ត្រី |
| ១៦២ - | លោក | ចាប | ផៃ | មន្ត្រី |
| ១៦៣ - | លោក | ម៉ឹង | កុសល | មន្ត្រី |
| ១៦៤ - | លោក | វិន | ឆាយ | មន្ត្រី |
| ១៦៥ - | លោក | ចៅ | សាង | មន្ត្រី |
| ១៦៦ - | លោក | ម៉ក់ | ផលឡៃ | មន្ត្រី |
| ១៦៧ - | លោក | ចេង | ឆូន | មន្ត្រី |
| ១៦៨ - | លោក | ឡេង | បូផា | មន្ត្រី |
| ១៦៩ - | លោក | ហែម | សុន | មន្ត្រី |
| ១៧០ - | លោក | ចិន | សារ៉ាត | មន្ត្រី |
| ១៧១ - | លោកស្រី | ស៊ីម | សុភា | មន្ត្រី |
| ១៧២ - | លោក | នួន | រិន | មន្ត្រី |
| ១៧៣ - | លោក | យូ | សុខា | មន្ត្រី |
| ១៧៤ - | លោក | ជា | ធនឧត្តរី | មន្ត្រី |
| ១៧៥ - | លោក | នី | សំណាង | មន្ត្រី |
| ១៧៦ - | លោក | សុខ | ជា | មន្ត្រី |
| ១៧៧ - | លោក | លី | គៀប | មន្ត្រី |

| | | | | |
|---|---|---|---|---|
| ១៧៨ - | លោក | គ្រួច | សាមឿន | មន្ត្រី |
| ១៧៩ - | លោកស្រី | អ៊ិន | វណ្ណា | មន្ត្រី |
| ១៨០ - | លោកស្រី | អ៊ិក | ស៊ីថា | មន្ត្រី |
| ១៨១ - | លោក | ចាន់ | សុភាព | មន្ត្រី |
| ១៨២ - | លោក | គង់ | សារី | មន្ត្រី |
| ១៨៣ - | លោក | គង់ | ញឹល | មន្ត្រី |
| ១៨៤ - | លោក | គង់ | សម្បត្តិ | មន្ត្រី |
| ១៨៥ - | លោក | ប៊ុន | ឈាង | មន្ត្រី |
| ១៨៦ - | លោក | តុប | តែម | មន្ត្រី |
| ១៨៧ - | លោក | កង | ឆ្លូក | មន្ត្រី |
| ១៨៨ - | លោកស្រី | ហែម | សុគុណពិសី | មន្ត្រី |
| ១៨៩ - | លោក | កៅ | មនោ | មន្ត្រី |
| ១៩០ - | លោក | ម៉ី | ធី | មន្ត្រី |
| ១៩១ - | លោក | ដុង | សុខ | មន្ត្រី |
| ១៩២ - | លោក | អេង | សុផាត | មន្ត្រី |
| ១៩៣ - | លោក | ថន | សំប៊ុរ | មន្ត្រី |
| ១៩៤ - | លោក | ញ៉ែម | សៅគ្រី | មន្ត្រី |
| ១៩៥ - | លោក | សុខ | សាវុធ | មន្ត្រី |
| ១៩៦ - | លោក | ញឹម | សារុន | មន្ត្រី |
| ១៩៧ - | កញ្ញា | យិន | បុប្ផា | មន្ត្រី |
| ១៩៨ - | លោក | គឹម | សំអាន | មន្ត្រី |
| ១៩៩ - | លោក | គិន | ឃ៉ាន | មន្ត្រី |
| ២០០ - | កញ្ញា | សុខ | សៅវ៉ៈ | មន្ត្រី |
| ២០១ - | លោក | ម៉ិច | សុខុម | មន្ត្រី |
| ២០២ - | លោកស្រី | ឈៀង | សុចិណ្ណា | មន្ត្រី |
| ២០៣ - | លោក | ខៀវ | ចំរើន | មន្ត្រី |
| ២០៤ - | លោក | ភា | សារិត | មន្ត្រី |
| ២០៥ - | លោក | ហោ | អាយ | មន្ត្រី |
| ២០៦ - | លោក | ហ៊ឹង | ចូច | មន្ត្រី |

| | | | | |
|---|---|---|---|---|
| ២០៧ - | លោក | ម៉ៅ | សុខា | មន្ត្រី |
| ២០៨ - | លោក | ឈាង | វណ្ណៈ | មន្ត្រី |
| ២០៩ - | លោក | សៅ | សុភារ៉េន | មន្ត្រី |
| ២១០ - | លោក | ចក់ | កុសល | មន្ត្រី |
| ២១១ - | លោក | សែង | អរុណ | មន្ត្រី |
| ២១២ - | លោក | ស៊ី | សុមិត្ត | មន្ត្រី |
| ២១៣ - | លោកស្រី | សូលី | វណ្ណានី | មន្ត្រី |
| ២១៤ - | លោក | ម៉ែន | ស៊ីនួន | មន្ត្រី |
| ២១៥ - | លោក | យូ | ភន | មន្ត្រី |
| ២១៦ - | លោក | គី | សុផាន | មន្ត្រី |
| ២១៧ - | លោក | កែវ | ហុង | មន្ត្រី |
| ២១៨ - | លោក | សួស | សុតាំក្រ | មន្ត្រី |
| ២១៩ - | លោក | ធឹក | សារឿន | មន្ត្រី |
| ២២០ - | លោក | ឆាំង | សុផាត | មន្ត្រី |
| ២២១ - | លោក | នួវ | ស៊ីថា | មន្ត្រី |
| ២២២ - | លោក | ឱ | សារឿន | មន្ត្រី |
| ២២៣ - | លោក | មុំ | ម៉ាលិកា | មន្ត្រី |
| ២២៤ - | លោក | ឡេង | សារឿន | មន្ត្រី |
| ២២៥ - | លោក | អ៊ុក | ស៊ីន | មន្ត្រី |

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពត៌មាន ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ០៤ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១និងមាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២០៩ អនក្រ.តត - ១៩

## អនុក្រឹត្យ

ស្តីពី

## ការផ្ទេរក្របខ័ណ្ឌ តែងតាំងមុខតំណែង និងឋានន្តរសក្តិនាយទាហាន

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសម្រួលតួនាទី ភារកិច្ច និង រចនាសម្ព័ន្ធចាត់តាំងអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ

-បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ

-យោងតាមការងារចាំបាច់

### សំរេច

**មាត្រា ១ :** ត្រូវបានផ្ទេរ និងតម្លើងឋានន្តរសក្តិវរៈសេនីយឯកជូនលោកវេជ្ជបណ្ឌិត **ឈឹម សៅគី** ជាជំនួយការផ្ទាល់របស់ឯកឧត្តម ឧត្តមសេនីយ៍ឯក **មល់ រឿប** ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី នាយរងសេនាធិការចម្រុះ នាយកដ្ឋានស្រាវជ្រាវចារកិច្ច អគ្គបញ្ជាការដ្ឋាន កងយោធពលខេមរភូមិន្ទ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី-សហរដ្ឋមន្ត្រីក្រសួងការពារជាតិ-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ-អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ សហរដ្ឋមន្ត្រី-រដ្ឋមន្ត្រី-រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ០៧ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**បានចម្លងជូន**

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ២

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២១០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល និងអគ្គនាយក នៃក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា «កម្ពុជា រី»

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យ លេខ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យ លេខ១៩ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រម លេខជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រម លេខនស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យ លេខ១០៦/អនក្រ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យ លេខ០៧/អនក្រ/បក ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបង្កើតក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា- កម្ពុជា រី
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# សំរេច

**មាត្រា ១-**

តែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល និងអគ្គនាយក នៃក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា ហៅកាត់ថា «កម្ពុជា រី» ដូចមានរាយនាមខាងក្រោមៈ

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិត **ហង់ ជួនណារ៉ុន** | អគ្គលេខាធិការរង នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាប្រធាន |
| ២. ឯកឧត្តម **ខៀវ សារ៉េត** | អគ្គាធិការ នៃអគ្គាធិការដ្ឋានកិច្ចការតុលាការ នៃក្រសួងយុត្តិធម៌ | ជាសមាជិក |
| ៣. លោកបណ្ឌិត **ជា វ៉ាន់ដេត** | អនុប្រធាននាយកដ្ឋានទំនាក់ទំនងបរទេស នៃទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |
| ៤. លោក **ចន្ទ ប៊ុនឥន្ទ្រាវុធ** | ប្រធានការិយាល័យគ្រប់គ្រងកាស៊ីណូ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាអគ្គនាយក |

**មាត្រា ២-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងស្ថាប័នពាក់ព័ន្ធ ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា និងសាមីខ្លួនដែលមានចែងក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវបំពេញភារកិច្ចរបស់ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រាជធានីភ្នំពេញថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២ "ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

៚៚

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រមស្តីពីលក្ខិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតកំពង់ផែស្វយ័តក្រុងព្រះសីហនុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## ស ម្រេ ច

**មាត្រា ១** : តែងតាំងលោក **លូ គឹមឈុន** ជាអគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ សំរាប់អាណត្តិ ៣ ឆ្នាំបន្តទៀត ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែមេសា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

ចម្លងជូន :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Thouen / 2002

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ :.........១១១.......បទ.ប្រក

ភ្នំពេញ , ថ្ងៃទី២៤ ខែមេសាឆ្នាំ ២០០២

## ប្រកាស

## ស្តីពីការ បង្កើតក្រុមការងាររៀបចំច្បាប់ពព្រៀង លើវិស័យទូរគមនាគមន៍

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន

-បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញការងារចាំបាច់របស់ក្រសួង

## សំរេច

ប្រការ ១ : ត្រូវបានបង្កើតក្រុមការងារមួយ ដើម្បីរៀបចំច្បាប់ពព្រៀងស្តីពីវិស័យទូរគមនាគមន៍ ដែលមានសមាសភាពដូចខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១-ឯកឧត្តម | គួយ | គឹមស៊ា | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២-ឯកឧត្តម | ឡា | ណារ៉ាត | អនុរដ្ឋលេខាធិការ | អនុប្រធាន |

កាច់ជ្រុងវិថីលេខ ១៣ និង ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
ទូរស័ព្ទ: (៨៥៥) ~~២៣-៤២៦៥១០~~/៤២៦៥១០
ទូរសារ: (៨៥៥) ២៣-៤២៦៩៩២/៤២៦០១១

៣-លោក គង់ សេង ទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រី សមាជិក

៤-លោក គុប សុខខួច ប្រធាននាយកដ្ឋាននយោបាយទូរគមនាគមន៍និយ័ត សមាជិក

៥-កញ្ញា ឌៀ ម៉ាយគៀង អនុប្រធាននាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ សមាជិក

៦-លោក វៀល ដារី ប្រធានការិយាល័យ នៃ នាយកដ្ឋាននយោបាយទូរគមនាគមន៍និយ័ត និង ទំនាក់ទំនងអន្តរជាតិ សមាជិក

៧-លោក គិត ស្រ៊ាង មន្ត្រីការិយាល័យនិតិក្រម នៃ នាយកដ្ឋាននយោបាយទូរគមនាគមន៍និយ័ត និង ទំនាក់ទំនងអន្តរជាតិ សមាជិក

**ប្រការ ២ :** ក្រុមការងារនេះមានភារៈកិច្ច ដើម្បីពិនិត្យ និង សំរាំងច្បាប់ស្តីពីវិស័យទូរគមនាគមន៍ ជាភាសាអង់គ្លេស និង ជាភាសាខ្មែរ រួចដាក់ជូន ឯកឧត្តមរដ្ឋមន្ត្រី ដើម្បីពិនិត្យ និង សុំយោបល់សំរេច ។

**ប្រការ ៣ :** ក្រុមការងារនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ ឯកឧត្តមប្រធាន ។

**ប្រការ ៤ :** រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារ នៃ ប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ :** ខុទ្ទកាល័យ-អធិការដ្ឋាន-នាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ-នាយកដ្ឋាននយោបាយទូរគមនាគមន៍និយ័ត និងទំនាក់ទំនងអន្តរជាតិ និង សាម៉ីខ្លួនត្រូវទទួលបន្ទុកអនុវត្តន៍តាមខ្លឹមសារ នៃប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស្វរ-ឃុន

កន្លែងទទួល

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៥ " ដើម្បីអនុវត្តន៍ "
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ : ១១៣ បទ..........

ភ្នំពេញ ថ្ងៃទី២៩ ខែ មេសា ឆ្នាំ ២០០២

## ប្រកាស

## ស្តីពីការតភ្ជាប់ខ្សែបណ្តាញទូរស័ព្ទ

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស រកត ១១៩៨ ៧២ចុះថ្ងៃទី៣០ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាព រាជរដ្ឋាភិបាលកម្ពុជា។
- បានឃើញព្រះរាជក្របេពេខ ០២.នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។
- បានឃើញព្រះរាជក្រម នសរកម ០១៩៦-២០ ចុះថ្ងៃទី ២៤ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។
- បានឃើញអនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។
- បានឃើញសេចក្តីសំរេចលេខ ១៥៤ សសរ ចុះថ្ងៃទី ១១-១២-៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីស្តីពីឋានានុក្រមគ្រប់គ្រងតម្លៃ។
- បានឃើញអនុសាសន៍ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងលិខិតលេខ១៣០០សហវចុះថ្ងៃទី៣មេសាឆ្នាំ២០០២។
- បានឃើញសេចក្តីសម្រេចរបស់អង្គប្រជុំ នៃ ក្រសួងប.ទ.ជាមួយប្រតិបត្តិករទាំងអស់និងនាថ្ងៃទី ២៥.៤.០២។

## សម្រេច

### ១- និយមន័យ

នៅក្នុងបទបញ្ញត្តិនេះ :

១.១ និយ័តករ (Regulator) គឺជាក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដែលមានភារកិច្ចបង្កើតនិងអនុវត្ត បទបញ្ញត្តិក្នុងវិស័យទូរគមនាគមន៍ ។

១.២ គណនេយ្យផ្ទាល់ (Direct Accounting) មានន័យថាការទូទាត់ប្រាក់ដែលត្រូវធ្វើដោយផ្ទាល់រវាងបណ្តាញ បញ្ជូនដើមនិងបណ្តាញទទួល ។

១.៣ ប្រតិបត្តិករ (Network Operator) មានន័យថាអង្គភាពដែលមានអាជ្ញាប័ណ្ណគ្រប់គ្រងនិងផ្តល់ សេវាទូរគមនាគមន៍ ។

### ២- សេចក្តីតម្រូវការនៃការតភ្ជាប់រវាងប្រព័ន្ធទូរស័ព្ទ

២.១- គ្រប់ប្រតិបត្តិករទាំងអស់មិនត្រូវធ្វើឱ្យមានការរាំងស្ទះដោយចេតនានូវចរន្តសេវាទូរស័ព្ទដែលហៅចេញពី ប្រព័ន្ធរបស់ខ្លួន ឬហៅមកប្រព័ន្ធរបស់ខ្លួន ឬឆ្លងកាត់តាមប្រព័ន្ធរបស់ខ្លួនឡើយ លើកលែងតែបានទទួលសេចក្តី អនុញ្ញាតិជាលាយល័ក្ខណ៍ អក្សរពីនិយ័តករ ។

២.២- ក្នុងករណីដែលប្រតិបត្តិករណាមិនព្រមបង់ថ្លៃតភ្ជាប់ទៅភាគីមួយទៀត ភាគីនោះអាចសុំការអនុញ្ញាតិ ពីនិយ័តករ បិទចរន្តសេវាជាមួយប្រតិបត្តករដែលមិនព្រមបង់នោះ ។

២.៣- គ្រប់ប្រតិបត្តិករទាំងអស់ត្រូវបញ្ជូនលេខទូរស័ព្ទដែលហៅចេញ និងលេខទូរស័ព្ទដែលគេហៅចូល (A and B numbers) ទៅប្រព័ន្ធទូរស័ព្ទដៃមួយទៀត ។

២.៤- ប្រតិបត្តិករទាំងអស់ត្រូវរក្សាគុណភាពសេវាហៅចេញឬចូល ទៅឬមកពីបណ្តាញដទៃយ៉ាងហោចណាស់ ឱ្យមានគុណភាពខ្ពស់ដូចក្នុងបណ្តាញរបស់ខ្លួន ។

២.៥- ប្រព័ន្ធរបស់ក្រសួងប.ទ.ត្រូវយកធ្វើជាចំណុចឆ្លងកាត់ (Transit point) លុះណាតែមានសេចក្តី អនុញ្ញាតិជាថ្មី ។

### ៣- ការផ្លាស់ប្តូរប្រព័ន្ធ

៣.១ ម្ចាស់ប្រព័ន្ធដែលមានបំណងកែប្រព័ន្ធដែលអាចតម្រូវឱ្យមានការកែប្រព័ន្ធប្រតិបត្តករដទៃ ត្រូវទទួលការ ឯកភាពពីគ្រប់ប្រតិបត្តករឯទៀត ហើយត្រូវជូន ដំណឹងជាលាយល័ក្ខណ៍អក្សរមកនិយ័តករ ។ ក្នុងករណីពុំមាន

ការឯកភាពអំពីប្រតិបត្តិករដទៃ និយ័តករត្រូវសម្រេចអនុញ្ញាតិឬមិនអនុញ្ញាតិឱ្យធ្វើការកែប្រព័ន្ធហើយនិងចង្អុលថាអ្នកណាជាអ្នកទទួលបន្ទុកលើថ្លៃកែនោះ យ៉ាងយូរ៦ខែគិតចាប់ពីថ្ងៃទទួលសំណើរ ។

## ៤- តម្លៃនៃការតភ្ជាប់

៤-១ __រវាងប្រព័ន្ធក្នុងប្រទេសនិងក្នុងប្រទេស__

៤-១-១ តម្លៃតភ្ជាប់រវាងប្រព័ន្ធចល័តនិងចល័តត្រូវស្មើនិង **៥.៨ សេន** ក្នុង១ នាទី ។

៤-១-២ តម្លៃតភ្ជាប់រវាងប្រព័ន្ធចល័តនិងអចល័ត ទាំងទៅឬមក ត្រូវស្មើនិង **២ សេន** ក្នុង១ នាទី ។

៤-១-៣ តម្លៃតភ្ជាប់រវាងប្រព័ន្ធអចល័តនិងអចល័តក្នុងដំបន់តែមួយ (In same area) ឬឆ្លងដំបន់ (Across areas) ហើយដំបន់ទាំងពីរនោះផ្សេងពីភ្នំពេញ ត្រូវស្មើនិង **១ សេន** ក្នុង១ នាទី ។

៤-១-៤ តម្លៃតភ្ជាប់រវាងប្រព័ន្ធអចល័តនិងអចល័តពីភ្នំពេញទៅដំបន់ផ្សេង ត្រូវស្មើនិង **២ សេន** ក្នុង១ នាទី ។

៤-១-៥ តម្លៃតភ្ជាប់រវាងប្រព័ន្ធអចល័តនិងអចល័តពីដំបន់ផ្សេងមកភ្នំពេញ ត្រូវស្មើនិង **១ សេន** ក្នុង១ នាទី ។

៤-២ __រវាងប្រព័ន្ធក្នុងប្រទេសនិងប្រព័ន្ធអន្តរជាតិ__

៤-២-១ តម្លៃតភ្ជាប់រវាងមាត់ច្រកអន្តរជាតិនឹងប្រព័ន្ធក្នុងប្រទេសត្រូវបានកំណត់ដូចតទៅ :

- ការហៅចូលពីបរទេស : ប្រព័ន្ធមាត់ច្រកអន្តរជាតិត្រូវបង់ឱ្យប្រព័ន្ធក្នុងប្រទេស **២សេន**ក្នុង ១នាទី ។
- ការហៅចេញទៅបរទេស : ប្រព័ន្ធក្នុងប្រទេសត្រូវបង់ឱ្យប្រព័ន្ធមាត់ច្រកអន្តរជាតិ **១០០%** នៃតម្លៃហៅចេញរបស់មាត់ច្រកអន្តរជាតិ ។

៤-៣ __តម្លៃឆ្លងកាត់ប្រព័ន្ធក្រសួងប.ទ.__

៤-៣-១តម្លៃឆ្លងកាត់ប្រព័ន្ធនៃក្រសួងប.ទ. ត្រូវស្មើនឹង **១** សេន ក្នុង១នាទីលើកលែងតែ :

- ប្រព័ន្ធក្រសួងប.ទ.ជាអ្នក ទទួលចរន្តសេវានោះ ឬ
- ចរន្តសេវានោះជាការហៅចេញទៅឬចូលមកពីអន្តរជាតិ ។

៤-៤ __តម្លៃនិយ័តករ__

៤-៤-១ ប្រតិបត្តិករត្រូវបង់ប្រាក់ **០.៣ សេន**ក្នុង១នាទី សម្រាប់និយ័តករ ចំពោះគ្រប់ចរន្តសេវាតភ្ជាប់រវាងប្រព័ន្ធ។

## ៥ ការគត់ត្រាទិន្នន័យ និងការទូទាត់ប្រាក់

៥-១ ចំនួននាទីដែលត្រូវទូទាត់ត្រូវគិតអំពីពេលដែលគេលើកទទួលរហូតត្រឹមពេលភាគីណាមួយដាក់ចុះ ។

៥-២ ចំនួននាទីសរុបត្រូវគិតលំអិតតាមចំនួនវិនាទីនៃការហៅសរុបទាំងអស់លើកលែងតែការហៅទៅអន្តរជាតិដែលគិត១៥វិនាទីម្តង ។

៥-៣ រយៈពេលចាក់សម្លេងផ្តល់ជាពតិមានដល់អតិថិជនមិនត្រូវរាប់បញ្ចូលក្នុងការគិតប្រាក់ឡើយ ។

៥-៤ គ្រប់ប្រតិបត្តិករត្រូវផ្តល់ចំនួននាទីសន្ទនាចូលនិងចេញប្រព័ន្ធខ្លួនទៅភាគីមួយទៀតដើម្បីធ្វើការទូទាត់ ។

៥-៥ ប្រតិបត្តិករត្រូវផ្តល់ទិន្នន័យជូននិយ័តករជា Compact Disc ឬបញ្ជូនតាមខ្សែកាបដោយផ្ទាល់ មិនអោយយឺតជាង១៥ថ្ងៃបន្ទាប់ពីដំណាច់ខែនិមួយៗ ។

៥-៦ ក្នុងករណីដែលប្រតិបត្តិករម្ខាងមិនផ្តល់ទិន្នន័យ ឬក៏ពុំមានមូលហេតុសមរម្យចំពោះការអាក់ខានមិនផ្តល់ទិន្នន័យទេ និយ័តករអាចចាត់ទុកទិន្នន័យរបស់ភាគីម្ខាងទៀតជាការត្រឹមត្រូវ ។

៥-៧ ការទូទាត់ប្រាក់រវាងប្រព័ន្ធពីរត្រូវធ្វើឡើងតាមការឯកភាពជាគូភាគី ឧទាហរណ៍យ៉ាងយូរក្នុងរយៈពេល៣ខែម្តង តែបើសិនមានការតវ៉ាលើតួលេខ ត្រូវធ្វើយ៉ាងយូរ១៥ថ្ងៃក្រោយពីនិយ័តករបានបញ្ជាក់ថាត្រឹមត្រូវហើយ ។

៥-៨ ប្រតិបត្តិករត្រូវអនុវត្ត"គណនេយ្យផ្ទាល់" រវាងបណ្តាញបញ្ជូននិងបណ្តាញទទួល ។

## ៦. ការផាកពិន័យនិងថ្ងៃចូលជាធរមាន

៦-១ ប្រតិបត្តិករត្រូវបានផ្តន្ទាទោសតាមច្បាប់ព្រហ្មទ័ណ្ឌក្នុងករណីក្លែងបន្លំទិន្នន័យកត់ត្រាប្រចាំខែ និងអាចឈានទៅដល់ការដកហូតអជ្ញាប័ណ្ណសំរាប់ធ្វើអាជីវកម្មផង ។

៦-២ ប្រតិបត្តិករមួយមានសិទ្ធផាកពិន័យជាការប្រាក់ **២%** ក្នុងមួយខែឬក៏តាមការឯកភាពគ្នាជាទ្វេភាគីជាមុនចំពោះការយឺតយ៉ាវបង់ប្រាក់របស់ប្រតិបក្ខករ ជាភាគីម្ខាងទៀតគិតចាប់ពីថ្ងៃដែលឯកភាពលើតួលេខហើយ ឬក៏ពីថ្ងៃដែលនិយ័តករបានបញ្ជាក់ថាត្រឹមត្រូវហើយ ។

៦-២ ប្រកាសនេះត្រូវចាប់អនុវត្តពីថ្ងៃទី១ឧសភាឆ្នាំ២០០២តទៅ ។

៦-៣ ប្រកាសណាពីមុនមកដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះចាត់ទុកជានិរាករណ៍ ។

រដ្ឋមន្ត្រី

ស៊ូ អាន

ចម្លងជូន :

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា -អគ្គលេខាធិការដ្ឋានរដ្ឋសភាជាតិ
-ទីស្តីការគណៈរដ្ឋមន្ត្រី -រាជកិច្ច
-ក្រសួងផែនការ -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
"ដើម្បីជ្រាបជាពតិមាន"
-គ្រប់អង្គភាពក្រោមឱវាទក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
-គ្រប់ប្រតិបត្តិករ
"ដើម្បីអនុវត្តន៍" ។
-ឯកសារ - កាលប្បវត្តិ